ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០១០........សហវ.......

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងចំពោះកិច្ច ដើម្បីវាយតម្លៃ ចរចា និងរៀបចំកិច្ចសន្យាទិញ-លក់មន្ទីរពេទ្យស្ត្រីឧត្តមភាព

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**<u>សម្រេច</u>**

**ប្រការ ១:** បង្កើតគណៈកម្មការអន្តរក្រសួងចំពោះកិច្ច ដើម្បីវាយតម្លៃ ចរចា និងរៀបចំកិច្ចសន្យាទិញ-លក់មន្ទីរពេទ្យស្ត្រីនគរទេព ដែលមានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១-ឯកឧត្តម **ឈុន សុគាភា** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-លោកជំទាវ **យក់ សម្បត្តិ** | រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | អនុប្រធាន |
| ៣-ឯកឧត្តម **ហាច អេន:** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា (កសហវ) | សមាជិក |
| ៤-ឯកឧត្តម **ឈឹម សារ៉ែត** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ (កសហវ) | សមាជិក |
| ៥-ឯកឧត្តម **នេត មុន្នី** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ (កសហវ) | សមាជិក |
| ៦-ឯកឧត្តម **ឈួន សំរិទ្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (កសហវ) | សមាជិក |
| ៧-ឯកឧត្តម **សុខ សំអេខ** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល | សមាជិក |
| ៨-ឯកឧត្តម **ហុក គីមចេង** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល នៃក្រសួងសុខាភិបាល | សមាជិក |
| ៩-លោក **កើត ឆែ** | អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ | សមាជិក |
| ១០-លោក **រស់ បរម** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា (កសហវ) | សមាជិក |
| ១១-លោក **ឡុង ជិនរិទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ (កសហវ) | សមាជិក |

**ប្រការ ២:** គណៈកម្មការអន្តរក្រសួងចំពោះកិច្ច មានតួនាទី ភារកិច្ច ដូចខាងក្រោម÷

- ធ្វើការសិក្សាលើគ្រប់ទិដ្ឋភាពទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ ព្រមទាំងកំណត់តម្លៃដែលរដ្ឋត្រូវទិញយកមន្ទីរពេទ្យស្រ្តីធនរទេព ដោយគិតបញ្ចូលទាំងតម្លៃអចលនវត្ថុ,ហេដ្ឋារចនាសម្ព័ន្ធ និងឧបករណ៍សម្ភារបរិក្ខារផ្សេងៗពីមូលនិធិធនរទេព ដើម្បីឱ្យរដ្ឋអាចធ្វើការគ្រប់គ្រង ចាត់ចែងនិងប្រើប្រាស់
- ចរចាថ្លៃ និងរៀបចំកិច្ចសន្យាទិញ-លក់
- មានសិទ្ធស្នើសុំការបំភ្លឺ និងការបញ្ជាក់បន្ថែមពីមូលនិធិធនរទេព (មន្ទីរពេទ្យធនរទេព) នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តការងាររបស់ខ្លួន។

**ប្រការ ៣:** គណៈកម្មការអន្តរក្រសួងចំពោះកិច្ច មានកាតព្វកិច្ច រាយការណ៍ជូន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេចទៅតាមដំណាក់កាល នៃនីតិវិធីហិរញ្ញវត្ថុ។

**ប្រការ ៤:** អនុប្រធាននិងសមាជិកត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ប្រធានគណៈកម្មការអាចផ្ទេរសិទ្ធជូនអនុប្រធានដឹកនាំការងារជំនួសក្នុងករណីមានធុរៈជាយថាហេតុ។ គណៈកម្មការអន្តរក្រសួងចំពោះកិច្ចនេះមានសិទ្ធប្រើត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់បំពេញការងារក្រោមក្របខ័ណ្ឌនៃសេចក្តីសម្រេចនេះ និងមានសិទ្ធអញ្ជើញតំណាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា ចូលរួមកិច្ចប្រជុំ ដើម្បីអនុវត្តការងារតាមការចាំបាច់។

**ប្រការ ៥:** នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការនិងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១១កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសុខាភិបាល
- សាលារាជធានីភ្នំពេញ
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ